**BBI0098**

# សម្ភាសន៍ជាមួយឈ្មោះ អ៊ុំ ហឿន ភេទប្រុស អាយុ៥១ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ អតីតទាហានលន់ នល់

មុខងារបច្ចុប្បន្នៈ អនុភូមិ

ស្រុកកំណើតនៅភូមិព្រៃចំការ ឃុំស្ពឺ-ខ ស្រុកបាភ្នំ ខេត្តព្រៃវែង

សព្វថ្ងៃរស់នៅភូមិសាស្តា ឃុំសាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង

ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៧:១៩

២៧ទំព័រ

វណ្ណៈ : ចឹងថ្ងៃទី២១ ខែមិនា ឆ្នាំ២០១១ ។ ចឹងជាដំបូងខ្ញុំសុំណែនាំខ្លួនថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ។ ហើយខ្ញុំមក ខ្ញុំចង់ដឹងពីប្រវត្តិរឿងរ៉ាវ តាំងពីដើមមក ពូរស់នៅយ៉ាងម៉េច ហើយនៅស្រុកកំណើតយ៉ាងម៉េច បានមកដល់នេះមានការលំបាក ឬក៏មានបញ្ហាអីខ្លះកើតឡើងចំពោះពូរហូតមកដល់ពេលនេះ ។ ហើយការសម្ភាសន៍របស់ខ្ញុំ.....(ស្តាប់មិនបាន) ។ ដូចថាខ្ញុំបានមកសម្ភាសន៍ពីពូយកទៅសរសេរ ទុកជាសៀវភៅ សម្រាប់កូនខ្មែរជំនាន់ក្រោយបានដឹង បានពូបានអត់ពូអនុញ្ញាត?

ហឿន : បាទ!

វណ្ណៈ : អត់អីទេ?

ហឿន : ...(ស្តាប់មិនបាន) ។

វណ្ណៈ : ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះអី?

ហឿន : ...(ស្តាប់មិនបាន) ។

វណ្ណៈ : អ៊ុំ ហឿន?

ហឿន : បាទ! ជីតាខ្ញុំ អ៊ុំ ។

វណ្ណៈ : ពូអាយុប៉ុន្មាន?

ហឿន : ៥៣ឆ្នាំ ។

វណ្ណៈ : ចុះប្រពន្ធពូឈ្មោះអីដែរ?

ហឿន : ដុំ ណាវ ។

វណ្ណៈ : ដុំ ណាវ?

ហឿន : បាទៗ ។

វណ្ណៈ : គាត់អាយុប៉ុន្មានដែរ?

ហឿន : អាយុ គ្រួសារខ្ញុំបងខ្ញុំម៉ាឆ្នាំ ។

វណ្ណៈ : ៥៨?

ហឿន : បាទ!

វណ្ណៈ : ចុះឪពុកពូឈ្មោះអី?

ហឿន : ឈ្មោះ ហម ។

វណ្ណៈ : ត្រកូលគាត់?

ហឿន : ត្រកូលគាត់អត់ស្គាល់ដែរ ។

វណ្ណៈ : ឈ្មោះ ហម?

ហឿន : បាទ!

វណ្ណៈ : ចុះម្ដាយ?

ហឿន : ម្ដាយឈ្មោះ ស៊ិន គិត ។

វណ្ណៈ : ស៊ិន គិត?

ហឿន : បាទ!

វណ្ណៈ : ចុះគាត់ទាំងពីរ សព្វថ្ងៃនេះនៅរស់ដែរ ឬយ៉ាងម៉េច?

ហឿន : ឪពុកស្លាប់ នៅតែម្ដាយ....(ស្ដាប់មិនបានឮច្បាស់) ។

វណ្ណៈ : ចុះពូបងប្អូនបង្កើតពូប៉ុន្មាននាក់?

ហឿន : ....(ស្ដាប់មិនបានឮច្បាស់) ។

វណ្ណៈ : ៧នាក់ សព្វថ្ងៃសល់ប៉ុន្មាន?

ហឿន : និយាយរួម ទើបស្លាប់ថ្ងៃមុនមួយ នៅសល់៦ ។

វណ្ណៈ : សល់៦ ។ ចុះកូនចៅពូវិញ កូន?

ហឿន : ....(ស្ដាប់មិនបានឮច្បាស់) ។

វណ្ណៈ : ស្រីប៉ុន្មាន?

ហឿន ៖ ស្រី២.......(ស្ដាប់មិនបានខ្យល់) ។

វណ្ណៈ ៖ ស្រី២ ចុះកាលពីតូចពូរៀនបានថ្នាក់ណា?

ហឿន ៖ ខ្ញុំនិយាយរួមទៅដូចវាមិនបាន ចាំមើលសម័យយើងពីសង្គមនឹង ខ្ញុំរៀនថ្នាក់ទី១២ទេ ទី១២ស្មើនឹងថ្នាក់ទី១....(ស្ដាប់មិនបានខ្យល់) ។ សម័យយើង សម័យ៣ឆ្នាំនឹង រៀនបានថ្នាក់ទី៣ដែរ នៅភូមិ ដល់រួចហើយ ថាគេបញ្ជូនទៅកងចល័តទៅ លែងបានរៀន។ កងចល័តរែកទំនប់ប្រឡាយណា ។

វណ្ណៈ ៖ រៀនថ្នាក់ទី៣នឹងកាលនឹង?

ហឿន ៖ កាលសម័យ៣ឆ្នាំ សម័យប៉ុលពតនឹង ។

វណ្ណៈ ៖ អានឹងគេរាប់ពីតូចវិញហើយ?

ហឿន ៖ បាទ!

វណ្ណៈ ៖ កាលមុនគេរាប់ពីធំចុះមកក្រោម?

ហឿន ៖ ហ្នឹងហើយ ។

វណ្ណៈ ៖ ដល់ពេលសម័យខ្មែរក្រហម គេរាប់ពីតូចឡើងទៅវិញ?

ហឿន ៖ បាទ! ហ្នឹងហើយ ។

វណ្ណៈ ៖ ចឹងបានថ្នាក់ទី៣វិញ?

ហឿន ៖ ហ្នឹង ។

វណ្ណៈ ៖ ពូចេះអាន ចេះមើល?

ហឿន ៖ មើលបានខ្លះដែរ ប៉ុន្តែវារៀងខ្សោយដែរនឹង ប្រកបអីខ្លះចឹងដែរ ប៉ុនមើលបានសរសេរបាន បើត្រឹមលក់របស់របរ គិតលុយគិតកាក់អីអត់អីទេ បាន ។

វណ្ណៈ ៖ ចឹងពូកាលដែលពូនៅស្រុកភូមិពូនឹង ពូនៅភូមិអីដែរ?

ហឿន ៖ ភូមិព្រៃចំការ ។

វណ្ណៈ ៖ ភូមិព្រៃចំការ?

ហឿន ៖ បាទ!

វណ្ណៈ ៖ ហើយឃុំ?

ហឿន ៖ ឃុំស្ពឺ-ខ ។

វណ្ណៈ ៖ ស្ពឺ-ខ?

ហឿន ៖ បាទៗ ។

វណ្ណៈ ៖ ស្រុកៗ?

ហឿន ៖ ស្រុកបាភ្នំ ខេត្តព្រៃវែង ។

វណ្ណៈ ៖ ឆ្លងអ្នកលឿនតិចទៅដល់?

ហឿន ៖ បាទ! ទៅតាមនឹងឆ្លងសាលាឡាង.... ។

វណ្ណៈ ៖ ពូនៅភូមិអីឥឡូវ?

ហឿន ៖ ភូមិសាស្តា ។

វណ្ណៈ ៖ សាស្តា?

ហឿន ៖ បាទ! សាស្តា ។

វណ្ណៈ ៖ ឃុំ?

ហឿន ៖ ឃុំសាស្តា ស្រុកសំពៅលូន ។

វណ្ណៈ ៖ ខេត្ត?

ហឿន ៖ ខេត្តបាត់ដំបង ។

វណ្ណៈ ៖ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ត្រួសៗដូចថា កាលដែលពូនៅកាលពីតូចពូរៀន ហើយពូឈប់រៀន ពូទៅធ្វើអី អីនៅណា ពូនិយាយតាមដំណើរចឹងទៅ?

ហឿន ៖ ឈប់រៀននឹងមូលហេតុមកពីជំនាន់នឹង........(ស្តាប់មិនបានឮល់) ។

វណ្ណៈ ៖ សង្គ្រាម?

ហឿន ៖ មិនទាន់សង្គ្រាមទេ កាលនឹងនោះ សម័យប្រជាជាតិខ្ញុំអត់ទាន់ទេ សម័យប្រជាជាតិខ្ញុំនៅតូច ។ ដល់ចឹងសម័យគេហៅសម័យកសាង សម័យ៣ឆ្នាំ អានឹងខ្ញុំនៅកងចល័តៗនៅស្រុកបាភ្នំ កងចល័តនៅទ្រង់ខ្វា កន្លែងការដ្ឋានទ្រង់ខ្វា ។

វណ្ណៈ ៖ សម័យកសាងសម័យ៧៥ ។ ១៩៧៥ ខ្មែរក្រហមគ្រប់គ្រង?

ហឿន ៖ ៧៧ ។

វណ្ណៈ ៖ ៧៧?

ហឿន ៖ បាទ! ៧៧ ។

វណ្ណៈ ៖ ប៉ុន្តែយើងគិតថា សម័យកសាងនឹងខ្មែរក្រហមនឹង ទូទាំងប្រទេសពី៧៥ទៅ ។ ចឹងពី៧៥ នឹងទៅ ដល់ពេល៧៧ ពូធ្វើអី?

ហឿន ៖ ៧៧នៅធ្វើកងចល័ត ។

វណ្ណៈ ៖ ៧៧បានចូលកងចល័ត?

ហឿន : បាទ! គេបញ្ជូនទៅកងចល័ត ។

វណ្ណៈ : ចុះចេញពីកងចល័ត?

ហឿន : ចេញពីកងចល័តគេបញ្ជូនទៅហាត់នៅព្រៃវែង ។

វណ្ណៈ : ហាត់យោធានៅព្រៃវែង?

ហឿន : បាទ!

វណ្ណៈ : ម៉េចទៀតពូ?

ហឿន : ដល់រួចពីនឹងហើយ ក៏គេបញ្ជូនឲ្យទៅព្រំដែន យួនឯកើតទៅ ។

វណ្ណៈ : ទៅឆ្នាំណា?

ហឿន : ទៅ៧៧ ។

វណ្ណៈ : ទៅវ៉ៃនៅព្រំដែន ការពារព្រំដែន?

ហឿន : បាទ! ការពារព្រំ ទៅការពារព្រំដែន ។

វណ្ណៈ : ការពារព្រំដែននឹង ពូទៅដល់គ្រាន់តែមើលការពារព្រំដែន ឬក៏ទៅដល់មានការឈ្លោះគ្នាអីហើយ?

ហឿន : ទៅ យើងអត់ឈ្លោះអីទេ យើងទៅការពារ ដូចថានៅយាមមើលនឹង ដើរល្បាតដើរអីចឹង ។

វណ្ណៈ : កាលនឹងពូចូលតែ បងប្អូនពូចូលតែពូម្នាក់ទេ ក៏ចូលប៉ុន្មាននាក់ដែរ?

ហឿន : បងប្រុសខ្ញុំមួយដែរ គាត់តាំងពី៧៣ ប៉ុនមកស្លាប់សម័យយើងនេះសង្គ្រាមដែរ តាមមើលខ្លួនរហូត ។ និយាយរួមម៉ាក្រុមគ្រួសារខ្ញុំ បាត់២នាក់ខ្ញុំ និងបងខ្ញុំ ។ ដល់ពេលខ្ញុំទៅហើយបាត់បងខ្ញុំ ។

វណ្ណៈ : បាត់តែម្នាក់ទេ?

ហឿន : បាទ! បាត់ជំនាន់សង្គ្រាម ។

វណ្ណៈ : បាត់បងឈ្មោះអី?

ហឿន : បាត់បងឈ្មោះ ហ៊ិរ អ៊ំ ហ៊ិរ ហ្នឹងបាត់រហូតអត់ដឹងដំណឹងឈឹង ។

វណ្ណៈ : គាត់ចូលបដិវត្ត៧៣?

ហឿន : បាទ!

វណ្ណៈ : បាត់ខ្លួនរហូត?

ហឿន : បាត់ខ្លួនរហូត ។

វណ្ណៈ :	ពូកាល៧៧នឹង ពូចូលទៅកងពលពីណាគេ?

ហឿន :	កងពលតាសោ ភឹម កងពលលេខ៥ ។

វណ្ណៈ :	លេខ៥ ពូចាំលេខ?

ហឿន :	បាទៗ ។

វណ្ណៈ :	ចឹងលោកពូនៅនឹង នៅព្រំដែនក្រោយមកមានសភាពការណ៍អីកើតឡើង?

ហឿន :	សភាពការណ៍កាលម៉ាជំនាន់នឹង ដែលឆ្នាំ៧៧នឹង មិនវៃគ្នាជាមួយយួននឹង ។

វណ្ណៈ :	៧៧ ៧៨នឹង?

ហឿន :	បាទ! យួនចូលមកដីយើង វៃគ្នាតាមព្រំប្រទល់ដែរ ខ្ញុំរបួសកាលជំនាន់នឹង របួសនៅក្មេង គ្មានដឹងអី កាលនឹងបើរត់ៗទៅណារួច យើងរត់អត់បានទេ ហើយចេះនៅ ចេះធ្វើនឹងគេនឹងឯង ។

វណ្ណៈ :	ចុះវៃកាលនឹងទាហានខ្មែរក្រហមបានកាំភ្លើង សម្ភារៈមកពីខាងណា?

ហឿន :	កាំភ្លើងជំនាន់នឹង គេថាបានពីប្រទេសចិន ។

វណ្ណៈ :	សម្ភារៈប្រទេសចិន ។ ចឹងកាលនៅយោធានឹង ការហូបចុកម៉េចដែរ?

ហឿន :	ការហូបចុក ហូបបាយយើង បាយវេចកញ្ចប់ស្បោង ។

វណ្ណៈ :	ប៉ុន្តែយើងបានហូបឆ្អែត គ្រប់គ្រាន់?

ហឿន :	ហូបវាធម្មតា ការយើងនៅមុខនឹង ជួនកាលយើងរៀងឆ្អែតទៅ ជួនកាលការខ្វះខាតចឹងដែរ ។

វណ្ណៈ :	ចឹងពូ កាលពូនៅធ្វើយោធាពី៧៧ ៧៨ទៅនឹង ពូដែលសុំគេមកលេងស្រុកកំណើត?

ហឿន :	អត់ដែរ ។

វណ្ណៈ :	ម៉េចបានពូមិនសុំ?

ហឿន :	មិនហ៊ាន ។

វណ្ណៈ :	ចឹងនៅក្នុងអង្គភាពនឹងវិន័យតឹង?

ហឿន :	ហ៎! វិន័យវាមិនដឹងយ៉ាងម៉េច ប៉ុនចេះតែខ្លាចគេ យើងនៅក្មេងនោះ អត់ហ៊ានសុំគេតែម្តង របួតទាល់តែខ្ញុំរបួសនឹង របួតទាល់តែពេទ្យដឹករបួតមកព្រំដែនលិចនឹង របួតដល់យើងត្រូវគ្នា បានយើងទៅលេងស្រុក ២០ឆ្នាំច្បាយ ។

វណ្ណៈ :	ចឹងកាលដែលពូនៅវៃជាមួយវៀតណាម ជាមួយយួននឹង កាលនឹងដូចថាកងពលពូមានគ្នាប៉ុន្មាននាក់ដែរ?

ហឿន : កងពល ខ្ញុំអត់ដឹងដែរ កាលនឹងខ្ញុំនៅក្មេងៗ អត់ដឹងៗ តែអតីតកងពលលេខ៥ ទេ ។

វណ្ណៈ : ពេលដែលវ៉ៃគ្នានឹង ពូជួបបញ្ហាអីខ្លះដែរ ដូចថាខាងខ្មែរក្រហម......(ស្តាប់មិនបាន) ?

ហឿន : ................(ស្តាប់មិនបាន) មេបញ្ជាការខ្ញុំៗ នៅសមរភូមិក្រោយ ដូចថានិរសាទេ គាត់ឲ្យឡើងទៅមើលៗ គេវ៉ៃដល់ណាៗ ។ ដល់ទៅៗ ត្រូវគេបាញ់មកត្រូវបណ្តោយ ។

វណ្ណៈ : ចឹងមានដែលចាប់បានទាហានយួនទេ?

ហឿន : ម៉ាជំនាន់នឹងគឺ ព្រោះក្រោយមក....(ស្តាប់មិនបាន) ។

វណ្ណៈ : ពូទៅបានប៉ុន្មានឆ្នាំបានរបួស?

ហឿន : មិនទាន់បានម៉ាឆ្នាំ បញ្ជូនទៅបានប៉ុន្មានខែ........(ស្តាប់មិនបានខ្យល់) នៅខ្ទីរហូតគ្មានដឹងអីហើយនឹកឃើញថាបើរត់មិនបានជួបម៉ែឪទេសម័យនឹង ដូចបងឯងដឹងសម័យនឹងតែរត់គេវ៉ៃចោល ។ ដល់ហើយចេះទ្រាំទៅ ចេះខ្លាចចេះសុខចិត្តថាទ្រាំៗទៅ ក្រែងលរបានជួបម៉ែឪ បានជួបមែន ដូចក្តីប្រាថ្នា អ្នករត់ទៅអត់បាន ។

វណ្ណៈ : អ្នករត់ទៅវ៉ៃចោល?

ហឿន : បាទ!

វណ្ណៈ : កាលពូទៅនឹង កន្លែងទ័ពនឹង មានគេចាប់ខ្លួនខ្លះ ឬមានគេបាត់ខ្លួនខ្លះដែរអត់ កន្លែងពូនៅយោធាពូនឹង?

ហឿន : ខ្ញុំអត់ដឹងដែរ ជំនាន់នឹង ។

វណ្ណៈ : ចុះពេលដែលគេចាប់សោ ភឹម?

ហឿន : ខ្ញុំរបួសដុតបាត់ហើយ ចឹងបានថាសំណាងល្អត្រង់...........................(ស្តាប់មិនបាន) ។ ដល់ខ្ញុំដាប់យួននៅបរវេលទៀតខ្ញុំ ប៉ុន្តែយួនអត់ធ្វើអីជំនាន់នឹង គេនយោបាយនោះ ដាប់យួននៅបវេលប្រជាជនគាត់ជួយខ្ញុំ គាត់ថា...........(ស្តាប់មិនបាន) នៅបូព៌ា នៅបស្ទឹមអីទៅ ប៉ុន្តែខ្ញុំនៅបូព៌ាស្រេចហើយនឹង បើថានៅនិរតីប្រជាជនស្អប់ ។ ដល់ចឹងប្រជាជនគាត់ល្អជាមួយយើង គាត់ប្រាប់ចឹងដែរ គាត់យកបាយយកអីឲ្យពួកខ្ញុំដែរ នៅដាប់នៅបវេលសាលាកាលេះពីដើម ផ្លូវសាលាវិទ្យាល័យ កាលនឹងមន្ទីរពេទ្យសម័យនឹងគេយកធ្វើមន្ទីរពេទ្យ ។ ដល់ចឹងប្រជាជន គាត់យកបាយយកទឹកអីឲ្យ កាលនឹងខ្ញុំដើរអត់រួចទេ ខ្ញុំរំកិលនឹង ៧៩ រត់៧៩ ដើរអត់រួចទេ ។

វណ្ណៈ : ចឹងខ្ញុំចង់សួរបកថាមុនរត់៧៩តិច ពេលដែលពូត្រូវរបួសហើយ គេបញ្ជូនពូមកន្លែងណាវិញ?

ហឿន ៖ បញ្ជូនមកពេទ្យនៅភ្នំពេញ ដឹកមកពេទ្យនៅភ្នំពេញ ។

វណ្ណៈ ៖ ពេទ្យៗណា?

ហឿន ៖ ពេទ្យ១៧ ។

វណ្ណៈ ៖ ពេទ្យ១៧ មេសា?

ហឿន ៖ បាទ!

វណ្ណៈ ៖ ពូដេកពេទ្យ១៧មេសា ដារបួសហើយគេបញ្ជូនពូទៅណាវិញ?

ហឿន ៖ កាលនឹងយួនបុកមកពេទ្យដឹករហូត ខ្ញុំដើរអត់រួចទេ ដឹករត់មកព្រៃរហូត ដើរអត់រួចដផង៣ឆ្នាំ មើល៧៧ ៧៩ខ្ញុំដើរមានទាន់រួចទេ ទាស់ចង្កេះ អស់ឆ្អឹងខ្នង ។

វណ្ណៈ ៖ ចឹងពេទ្យដឹកឡានមក មកព្រំដែន?

ហឿន ៖ ដឹកឡានមកចោលៗនៅព្រៃនឹង ចោលនៅព្រៃទៀត ។

វណ្ណៈ ៖ ចោលនៅណា ដឹកដល់ណា?

ហឿន ៖ ដឹកមកដល់យើងនេះតាង៉ុកយើង បារាំងធ្លាក់ ។

វណ្ណៈ ៖ អូ! ឆ្ងាយដែរ?

ហឿន ៖ បាទ! ចូលដល់ដីរំអីនឹងគេ ។

វណ្ណៈ ៖ តាង៉ុក បារាំងធ្លាក់?

ហឿន ៖ បាទ!

វណ្ណៈ ៖ ម៉េចបានគេហៅបារាំងធ្លាក់កាលនឹងពូ?

ហឿន ៖ ដឹងម៉េច ជំនាន់បារាំងៗគេមកធ្លាក់នឹងបានចឹង បាទ!អាចចឹង ។

វណ្ណៈ ៖ ចឹងគេហៅតៗគ្នា?

ហឿន ៖ បាទ! ហៅត ថាបារាំងធ្លាក់ៗ ។

វណ្ណៈ ៖ ចឹងពូ៧៩ពូរបួស ហើយបានខាងពេទ្យនឹងគេដឹកមកដល់ព្រំដែន?

ហឿន ៖ បាទ! ដឹករត់មកកាត់ព្រៃកាត់ប្រាំង ។

វណ្ណៈ ៖ គ្នាច្រើនទេ ជិះឡាន?

ហឿន ៖ ............(ស្តាប់មិនបាន) អ្នកខ្លះស្លាប់ពេញព្រៃ របួសអ្នករស់ចេះមកទៅ អ្នកស្លាប់ចេះស្លាប់ ជំនាន់នឹងចេះតាមគេតាមឯងមកទៅ ។ ហើយយើងម៉ាជំនាន់នឹង ពេទ្យដូចថាគាត់អានឹងពីមុនស្នេហាជាតិចេះតែយកមកទៅខ្មែរគ្នាឯង ជំនាន់ឥឡូវមិនដឹងយ៉ាងទេ ។.........(ស្តាប់មិនបាន) ។ បើពេទ្យយកមក ខ្ញុំក៏មិនបានរស់ បើថាគេចោលនឹងព្រៃដឹងនៅព្រៃ ។

វណ្ណៈ : បើសូវចោលនៅពេទ្យក្នុងភ្នំពេញអត់អីវិញ?

ហឿន : បាទ! បើនៅក្នុងម៉ង អានឹងមានអី ។

វណ្ណៈ : គេរំដោះហើយ ដូចថាអ្នករបួស.......(ស្តាប់មិនបាន) ។

ហឿន : ចុះខ្ញុំមិនចឹង...........(ស្តាប់មិនបាន) ខ្លះដើរចេញ ខ្លះនាំគ្នាផ្អើល វារចេញ សែង......... (ស្តាប់មិនបាន) ។ ប៉ុន្តែក៏អត់អីហូបដែរ ហើយរបួសយើងអត់ទាន់ជាទៀត ។

វណ្ណៈ : ហើយយួនមកទាន់ពូដែរ?

ហឿន : ទាន់ទាំងអស់ មក ។

វណ្ណៈ : ហេតុអីពូមិនមានចិត្ត ដូចថាមកទាន់ចឹង មិនមានចិត្តត្រឡប់ក្រោយវិញ?

ហឿន : ត្រឡប់ក្រោយអី បើដើរមិនរួចផង ។

វណ្ណៈ : ចុះយួនអត់មានវិធីដាក់ឡានដាក់អី?

ហឿន : អត់ទេ ។

វណ្ណៈ : គេស្រួតវ៉ៃមកមុខទៀត?

ហឿន : វ៉ៃមកមុខ យួនវាទៅមកៗតាមនឹងប៉ុន្តែយើងអត់បាយអត់ទឹក ហើយក៏គេអត់ដឹងដែរ អ្នកណាស្លាប់ៗ អ្នកណារស់ចេះតែរស់ទៅ ។ ហើយខ្ញុំនឹងដោយសារកងទ័ពវ៉ៃចូលយកមកទេ បានមកដល់នេះ ។

វណ្ណៈ : កងទ័ពខាង?

ហឿន : កងទ័ពពួកខ្មែរក្រហម ចុះកាលនឹងនៅតស៊ូវ៉ៃគ្នាទៅមកៗ ។ ដល់ហើយទ័ពវ៉ៃចូលយកមកទៀត ដឹកខ្ញុំមកព្រៃតាមព្រៃនឹងទៀតទៅ ។

វណ្ណៈ : មកដល់ណាទៀតទៅ?

ហឿន : មកដល់យើងព្រំដែនមកដល់ ។

វណ្ណៈ : មកដល់កន្លែងណា?

ហឿន : បាទ! ព្រំដែនថៃ។ ដល់រួចហើយខ្ញុំទៅនៅជំរំកាកបាទ បានទៅនៅជំរំស្រះកែវខ្លះ៦-៧ខែបើខ្ញុំដើរ អត់រួចផង ចេះទៅៗ ។ កាលនឹងពេទ្យក៏រត់ចោលអស់ ។

វណ្ណៈ : ជំរំស្រះកែវ?

ហឿន : បាទ!

វណ្ណៈ : មកដល់ជំរំស្រះកែវយើងលែងអីហើយ យើងមានរបបហូបចុក?

ហឿន : បាទ! របបហូប កាកបាទគេឲ្យ ចែកចាយ ។

វណ្ណៈ : នៅឆ្នាំ៧៩ដដែល?

ហឿន : ៧៩ ។

វណ្ណៈ : ចឹងពូមកដល់ព្រំដែន ដោយសារពួជិះឡានជិះអីចឹងមិនយូរទេ មកដល់ព្រំដែនដូចថា?

ហឿន : ឡានរទេះគោទៀត បើឡានទៅលែងរួចរទេះគោ.................(ស្តាប់មិនបានខ្យល់) ។

វណ្ណៈ : ប្រហែលប៉ុន្មានខែ ពូមកដល់ព្រំដែន?

ហឿន : ដូចមិនដល់ម៉ាខែទេ ។

វណ្ណៈ : ព្រោះយើងជិះឡាន?

ហឿន : វារបៀបម៉ាថ្នាក់ៗ ទោះបីយើងអត់ជិះឡាន អ្នកខ្លះដើរថ្មើរជើងសុទ្ធ ដែលអ្នកគេដើររួច ប៉ុនខ្ញុំពេទ្យបេះដាក់រទេះ ។

វណ្ណៈ : កាលនឹងពូឃើញទេសភាពមនុស្សរត់មក ពេញព្រៃម៉ង?

ហឿន : ..........(ស្តាប់មិនបានខ្យល់).............អត់បាយ ។ ពីដើមមានអីសុទ្ធតែព្រៃ មានបំពង់ទឹកបញ្ឈរនឹង ខ្មោចស្លាប់នៅក្រោម ។ ខ្ញុំហើយ ខ្ញុំរុកកាប់ព្រៃធ្វើឃ្លាំង ធ្វើអីដាក់....(ស្តាប់ មិនបាន) ឆ្អឹងស្លាប់នៅក្រោម ស្លាប់ពេញព្រៃជិនាន់នឹង ។ ខ្ញុំរបួសដែរ ប៉ុនបេះឆ្លងកាត់ អាគ្រុនចាញ់នឹងរួច អត់អី ។

វណ្ណៈ : ជាពិសេសស្លាប់ដោយសារអត់បាយ ៧៩នឹង?

ហឿន : អត់បាយ អត់ទឹកនឹងម៉ង ពួកខ្ញុំនិយាយលេងសើចអី សុទ្ធតែសល់ពីស្លាប់ បើខ្ញុំវិញទៅជួប បងប្អូន ជួបអីមីងមាអី គាត់ថាសុទ្ធតែពួកឯងអាយុថ្ងៃហើយ ។

វណ្ណៈ : ចុះពូទៅជំរំស្រះកែវបានប៉ុន្មានខែ?

ហឿន : ខ្ទង់៦-៧ខែដែរនឹង ។

វណ្ណៈ : នៅជំរំស្រះកែវនឹង ពូហេតុអីពូមិនមានបំណងរត់ទៅក្រៅ?

ហឿន : គេរកយកទៅដែរនឹង ខ្ញុំទៅនៅកន្លែងកុមារកំព្រា ខ្ញុំប្រាប់បងឯងត្រង់ ប៉ុន្តែខ្ញុំខ្លាចអត់បានមកស្រុកវិញ កុំអីខ្ញុំឆ្ងាយទៅក្រៅ ។ នៅភូមិខ្ញុំទៅបាន២-៣នាក់ដែរនឹង នៅកាណាដា នៅអី រាល់ថ្ងៃទៅស្រះកែវជាមួយគ្នា កាលនឹងអាមេរិច-បារាំងដណ្តើមគ្នាដូចស្អីចឹង ។

វណ្ណៈ : ដណ្តើមយក?

ហឿន : បាទ! ខ្ញុំចូលមណ្ឌលកុមារកំព្រា ប៉ុន្តែយើងដូចថាគ្មាននិស្ស័យក៏ថាបានដែរកាលនឹងហើយ ម្យ៉ាងក្នុងចិត្ត ។

វណ្ណៈ : ពូខ្លាចអី ខ្លាចបែកឪពុកម្តាយ?

ហឿន ៖ បែកឪពុកម្ដាយខ្ញាចអត់បានមកស្រុកវិញ នឹកឃើញចេះ មិនដឹងប្រទេសយើងត្រូវចឹងអី វាមិននឹកស្មាន ។

វណ្ណៈ ៖ ដល់ពេលចឹងពូត្រឡប់?

ហឿន ៖ ខ្ញុំត្រឡប់ព្រំដែន មកដីខ្មែរ ។

វណ្ណៈ ៖ ពីណាទៅយកពីស្រះកែវមកវិញ?

ហឿន ៖ តាមជំនាន់នឹង ខ្ញុំអត់ដឹងដែរ គេមកៗនឹងគេទៅ ។

វណ្ណៈ ៖ ពូមកចេញពីស្រះកែវ ពូមកតំបន់ណា?

ហឿន ៖ មកតំបន់យើងភ្នំដីនេះ ។

វណ្ណៈ ៖ ភ្នំដីនៅកន្លែងណា?

ហឿន ៖ ដីថៃ នៅដីថៃកាលនឹង យើងមិនទាន់បានដីទេ ។

វណ្ណៈ ៖ ភ្នំដី?

ហឿន ៖ បាទ! ភ្នំដី ។

វណ្ណៈ ៖ ក្នុងដីថៃអានឹង?

ហឿន ៖ បាទៗ ។

វណ្ណៈ ៖ ពេលក្នុងដីថៃហើយ ក្រោយមកទៀតពូមកនៅណាទៀត?

ហឿន ៖ ក្រោយមកនៅតាមព្រំដែនយើង ដីយើង ។

វណ្ណៈ ៖ ព្រំដែននឹងព្រំដែនអី?

ហឿន ៖ ព្រំដែនថៃខ្មែរយើងនឹង ។

វណ្ណៈ ៖ ប៉ុន្ដែអាកន្លែងដែលពូមកនៅព្រំដែនថៃ-ខ្មែរនឹងគេហៅអី កាលពូនៅនឹង?

ហឿន ៖ គេហៅ មានកន្លែង៨០ គីឡូ១៣ គីឡូ១២ ។

វណ្ណៈ ៖ ៨០?

ហឿន ៖ បាទ!

វណ្ណៈ ៖ ហៅគីឡូ?

ហឿន ៖ ១៣ គីឡូ១២ ។

វណ្ណៈ ៖ ១២ចឹង?

ហឿន ៖ បាទ!

វណ្ណៈ ៖ ប៉ុន្ដែនៅខាងនឹង គេហៅម្ដុំសំពៅលូននឹង ចក្រី ឬក៏ម៉ាឡៃ ឬក៏ម៉េចពូៗមក?

ហឿន : អានឹង កាលនឹងអត់ទាន់រៀបចំស្រុកអីផង ។

វណ្ណៈ : អត់មានស្រុកមានអី?

ហឿន : បាទ! អត់ទេ សុទ្ធតែព្រៃ ។

វណ្ណៈ : ព្រៃសុទ្ធ?

ហឿន : បាទ!

វណ្ណៈ : ព្រៃខ្លាព្រៃដីរ?

ហឿន : បាទ! ព្រៃសុទ្ធ ។

វណ្ណៈ : ចុះពូមកដល់ជំរំដូចថាគីឡូ១៣ គីឡូ១២វិញនឹង ពូជាប្រជាជន ឬពូចូលទ័ពទៀត?

ហឿន : ខ្ញុំកាលនឹង តាំងពីរបួសនឹងមិនទាន់មានអង្គភាពទេ ដល់មកដល់នេះ គេឃើញយើងរបួស ពិការ គេឲ្យនៅចាំឃ្លាំង ។

វណ្ណៈ : ឃ្លាំង មានឃ្លាំងទៀត ក្នុងព្រៃនឹង?

ហឿន : បាទ! ឃ្លាំងអង្ករ ។

វណ្ណៈ : ឃ្លាំងអង្ករ ឃ្លាំងលេខប៉ុន្មានកាលនឹង?

ហឿន : បាទ! ឃ្លាំង ដែលគេហៅ៤០៥កាលពីមុន ។

វណ្ណៈ : ឃ្លាំងនឹងមានអង្ករ មានអាវុធទេ?

ហឿន : កាលជំនាន់នឹង ខ្ញុំអត់ដឹងដែរ ប៉ុនឃ្លាំងដែលខ្ញុំគេឲ្យនៅនឹងមានឃ្លាំងអង្ករ ។

វណ្ណៈ : ពូអត់ឡើងវ៉ៃទេ ពូមានរបួសចឹង?

ហឿន : រហូត និយាយរួមតាំងពីរបួសនឹងមក ខ្ញុំនៅខាងក្រោយ ។

វណ្ណៈ : ចុះរបបហូបចុកអីគេចែកឲ្យយើងហូបគ្រប់គ្រាន់?

ហឿន : ហូបគ្រប់គ្រាន់ ។

វណ្ណៈ : ហើយពូយកប្រពន្ធនៅ កាលនៅឃ្លាំង?

ហឿន : នៅទេ ខ្ញុំនៅ ។

វណ្ណៈ : ហើយកាលនឹង កាលជំនៀរគីឡូ១៣អីពីណាកាន់កាប់គ្រប់គ្រងពូ?

ហឿន : កាលនឹងពូអៀន ។

វណ្ណៈ : ប្រធានកងពល?

ហឿន : អូ!នេះប្រធានឃ្លាំង ។

វណ្ណៈ : ប្រធានឃ្លាំងពីណា?

ហឿន ៖ ដែលខ្មោចអៀន គាត់ស្លាប់ហើយ ។

វណ្ណៈ ៖ ពូអៀន?

ហឿន ៖ បាទ! ឃ្លាំងគេហៅ ។

វណ្ណៈ ៖ ឥឡូវគាត់ស្លាប់ហើយ?

ហឿន ៖ បាទៗ គឺឆ្នាំ១៣ ៨០៥លេខអន្តភាព ។

វណ្ណៈ ៖ ចុះប្រធានកងពលពូដឹង?

ហឿន ៖ ប្រធានកងពលៗកាលនឹង ដឹងកងពលប៉ុន្មានទេ មិនសូវចាំដែរ ។

វណ្ណៈ ៖ ប៉ុន្តែស្គាល់ឈ្មោះប្រធានកងពលទេ តានី កន ឬក៏ណា?

ហឿន ៖ តាកន គាត់ទទួលនៅក្នុងស៊ីសាផុននឹងទាំងមូលទាំងអស់ម៉ង តែកងពលមានច្រើនដែរជិតនាំ នឹង ។

វណ្ណៈ ៖ សូ ហុង?

ហឿន ៖ គាត់ពេទ្យទេ ។

វណ្ណៈ ៖ ខាងម៉ាខ្មៅទេ?

ហឿន ៖ អូ! ខាងនោះខ្ញុំអត់ដឹងដែរ ។

វណ្ណៈ ៖ ប៉ុន្តែពូនៅជិតទៀរសំពៅលូននេះ?

ហឿន ៖ បាទ! សំពៅលូន ។

វណ្ណៈ ៖ សំពៅលូន ពីណាប្រធានកងពល?

ហឿន ៖ កងពល បើមកយើងថ្មីៗសម័យយើងឥឡូវនេះ មានពូ ពុធពូអីនឹង ។

វណ្ណៈ ៖ ប៉ុន្តែចង់និយាយការសម័យតស៊ូ សម័យក្រោយ៧៩អីនឹងឆ្នាំ៨០ជាងអីនឹង?

ហឿន ៖ មានអ្នកណាមានតា៦៨ ។

វណ្ណៈ ៖ តាណា?

ហឿន ៖ គាត់ទទួលខុសត្រូវរួមម៉ង ។

វណ្ណៈ ៖ តាណា?

ហឿន ៖ តា៦៨ ។

វណ្ណៈ ៖ តា៦៨ពីណា?

ហឿន ៖ តាកនយើង ។

វណ្ណៈ ៖ តាកន ឈ្មោះតា៦៨ទៀត?

ហឿន : បាទ! លេខគាត់ពីមុនមក គាត់អ្នកដឹកនាំមានប្រជាជនគាំទ្រគាត់ មានតែគាត់នឹងឯង ប្រជាជនចូលចិត្ត ។ ហើយជំនាន់យើងសមាហរណកម្មនេះ មានបញ្ហាអីទេ គាត់នៅជាមួយប្រជាជនដដែល ។

វណ្ណៈ : ចុះតា៦៤ តានី កន នឹងគាត់ប្អូនសុន សេនបង្កើត?

ហឿន : បែបថាត្រូវជាប្អូន ។

វណ្ណៈ : ចុះកាលនឹងតាសុន សេន មកកាន់នៅនឹង?

ហឿន : គាត់មក ។

វណ្ណៈ : មកដែរ?

ហឿន : បាទ!

វណ្ណៈ : ពូស្គាល់តា សុខ គង់ទេ ឥឡូវគាត់អភិបាលឥឡូវ?

ហឿន : សុខ គង់នឹង តាគង់គាត់នៅ ស្គាល់តើ គាត់នៅខាងអភិបាល ។

វណ្ណៈ : ខាងកំរៀង?

ហឿន : បាទ!

វណ្ណៈ : គាត់ប្រធានកងពលខាងកំរៀង?

ហឿន : គាត់កងពលខាងនឹង ខាងកំរៀង ។

វណ្ណៈ : បែបខាងនេះ ប្រធានកងពលពីណាគេ ពូអត់ស្គាល់ទេ?

ហឿន : អត់ស្គាល់ ស្គាល់តែតាពុធ គាត់ពួកតែថ្មី តារុំតាអីណា ។

វណ្ណៈ : យើងអត់និយាយឥឡូវ ចាំនិយាយក្រោយ?

ហឿន : បាទ! ពីមុនមកមានដឹងថា ។

វណ្ណៈ : ....(ស្តាប់មិនបាន) តាកនស៊ីសាដុនក្តោប?

ហឿន : បាទ! សមរភូមិស៊ីសាផុនខាងត្បូងចិងទៅ មានគាត់ ។

វណ្ណៈ : ចឹងដូចថាសុន សេន គាត់ចេញចូលនេះដែរ?

ហឿន : បាទ! គាត់នៅជើង ពីត្បូងនៅនោះ តំបន់មួយខាងឧត្តរ......(ស្តាប់មិនបាន) ។

វណ្ណៈ : ចុះសុន សេន?

ហឿន : សុន សេន ខ្ញុំអត់ដឹងដែរ ។

វណ្ណៈ : ចុះពូខាងនឹង ថានៅក្នុងព្រៃមានគុកតាចាន់អី មានឬក៏មិនមានទេ មានខាងភ្នំព្រឹក្សទេ?

ហឿន : មាន ប៉ុន្តែកន្លែងនឹងម៉ាជំនាន់នឹងគេមិនហៅគុកទេ គេហៅកន្លែងអប់រំ ។

វណ្ណៈ : មន្ទីរអប់រំម៉េច?

ហឿន : អប់រំឧទាហរណ៍ មានអ្នកខូច មានអ្នកថាដែលគោរព........(ស្តាប់មិនបាន) អីចឹង យកមកអប់រំ ។

វណ្ណៈ : ចឹងនៅកន្លែងណា គេដាក់នៅកន្លែងមន្ទីរនឹង?

ហឿន : កន្លែងមន្ទីរដែរអប់រំនឹងនៅម៉ាជិតនាន់នឹងនៅកន្លែង៨៩ ។

វណ្ណៈ : ៨៩?

ហឿន : បាទ!

វណ្ណៈ : ពីណាគ្រប់គ្រងមន្ទីរនឹង?

ហឿន : តែម៉ាជិតនាន់នឹង តាចាន់យើង ។

វណ្ណៈ : តាចាន់?

ហឿន : បាទ! អប់រំចឹងទៅ ចេញទៅវិញចឹងទៅ កងទ័ពយើងក៏ដោយនឹង ។

វណ្ណៈ : កាលនឹងមានសម្លាប់ មានអីខ្លះទេ?

ហឿន : អត់មានទេ ។

វណ្ណៈ : ចុះអាមន្ទីរ២៥០នោះ គេថាក្នុងព្រៃដែរនោះ?

ហឿន : អានឹងខ្ញុំអត់ដឹងដែរ ។

វណ្ណៈ : ចឹង?

ហឿន : បាទ!

វណ្ណៈ : ហ្នឹងថាតាចាន់គ្រប់គ្រងដែរ? ចឹងនៅនេះក៏មានអ្នកទោស ក៏មានអីដែលនៅក្នុងនេះ?

ហឿន : ដូចតែគ្នាក្លួយសង្គមណា ដូចសង្គមណា បើមិនមានកន្លែងនឹងវាមិនងាយទេ ។

វណ្ណៈ : ចឹងដូចថានៅក្នុងសម័យនឹងយោធាក៏ដោយ ស្អីក៏ដោយ មិនមានប្រាក់ខែ?

ហឿន : អត់មានទេ ប៉ុនរបបគេបើកឲ្យហូប ។

វណ្ណៈ : ចឹងនៅ ខ្ញុំចង់ដឹងនៅខាងសំពៅលូននេះ មានគោលការណ៍នៅឆ្នាំ៩៣ ៩៤ ៩៥អីនឹងដូចថាជិតផ្តាច់ខ្លួនអីចឹង មានប្រមូលដូចថាសុនសេន គេចង់ប្រមូលទ្រព្យសម្បត្តិប្រជាជនម៉ាចំនួនដើម្បីឲ្យមានទឹកចិត្តឡើងវៃទៅខាងមុខ ដោយសារថាប្រជាជនយូរទៅៗគាត់បេះរកស៊ីជាមួយថៃជាមួយអី មានលុយមានកាក់អីលែងចង់ទៅច្បាំងអីចឹង ។

ហឿន : មានៗចឹងដែរ ។

វណ្ណៈ : ចុះមានការប្រមូលនឹងមែន ឬក៏មិនទាន់?

ហឿន ៖ ប្រមូល គ្រាន់តែដែនការអាចប្រមូល ប៉ុនអាចប្រមូលឡានដែរជំនាន់នឹង ។

វណ្ណៈ ៖ ចុះប្រជាជនអត់មានជំទាស់អីទេ?

ហឿន ៖ ចេះតែខ្លាចដែរ ម៉េចហ៊ាន ។ មានរទេះគោរទេះអីថាប្រមូលៗដាក់ម្ដុំដែរ ប៉ុនដល់ចឹងទៅខ្លះ ទៅក៏យកទៅដាក់ទៅ ខ្លះអត់ ។ ខ្ញុំអីវ៉ាន់មានរទេះគោដែរ ដល់គេឲ្យប្រមូលសមរទេះគោ ..........(ស្ដាប់មិនបាន) ។ ហើយខ្ញុំចេះថា មេក្បត់ប្រមូលរទេះគោណាមិនឲ្យប្រជាជនរក ស៊ីរកដឹកអី ។ ដឹងចឹង ចេះតែគិតឃើញចឹងដែរក្នុងចិត្ត ធម្មតារទេះគោសម្រាប់កសិករត្រូវ បើអត់ឲ្យមានរទេះគោទៀត មិនដឹងគ្នាបានអី ក្នុងចិត្តចេះតែគិតចឹង វាមិនដែលអ្នកណាប្រមូលរទេះគោ ។

វណ្ណៈ ៖ ពូគិតថា មកដល់សម័យនេះហើយប្រមូលចឹង តិចត្រឡប់ទៅរកសម័យការដើមវិញ ពូមានគិតចឹងទេ?

ហឿន ៖ អានឹងវាចេះនឹកឃើញចឹងៗដែរ ប៉ុនក្នុងចិត្តយើងមិនហ៊ាននិយាយ ។

វណ្ណៈ ៖ ចុះនេះតាប៉ុល ពត, តាខៀវ សំផននេះ គាត់អត់មានចេញមុខមកទេ?

ហឿន ៖ អត់ទេ ។

វណ្ណៈ ៖ ចុះតាចាន់នៅនេះ គាត់គ្រាន់តែកាន់កុករហូតទៀត គាត់អត់មានធ្វើអីទៀតទេ?

ហឿន ៖ អត់មាន ។

វណ្ណៈ ៖ ឥឡូវគាត់រស់នៅក្នុងភូមិជាមួយពូ ជិតៗពូនឹងដែរ?

ហឿន ៖ នៅភូមិខុសគ្នា ។

វណ្ណៈ ៖ គាត់នៅភូមិអី?

ហឿន ៖ នៅភូមិចំការល្ហុង ។

វណ្ណៈ ៖ ចុះពូដល់ពេលពូមកឃើញកាលមុននៅសំពៅលូនអី ពីដើមអី ពូគិតមើលគ្មានផ្ទះសំបែងអី សល់ពីសង្គមចាស់..............(ស្ដាប់មិនបាន) ។ ព្រៃសុទ្ធ គ្មានភូមិកំណើត គ្មានបែងចែកភូមិដូចឥឡូវចឹងទេ អត់មានទេ? ចឹងនៅនេះចូលសមាហរណកម្មឆ្នាំណា?

ហឿន ៖ ឆ្នាំ៩០ប៉ុន្មានទេ ខ្ញុំភ្លេចដែរ ទាល់តែមើលសៀវភៅ ៩០ប៉ុន្មានអត់សូវចាំដែរនឹង ។

វណ្ណៈ ៖ ចឹង៩៣អ៊ុនតាក់ដំបូងបោះឆ្នោតលើកទី១បានបោះទេ?

ហឿន ៖ ខ្ញុំ?

វណ្ណៈ ៖ ហ្នឹងហើយប្រជាជនក្នុងភូមិ?

ហឿន ៖ បោះរហូត និយាយរួមបោះរហូត ។

វណ្ណៈ ៖ យី! នៅមិនទាន់ផ្ដាច់ខ្លួនបោះមិនបានទេ កន្លែងនឹង?

ហឿន ៖ ហ៊ឺ! ដល់ពេលនេះហើយ អាពេលដែលយើងនេះហើយ ។

វណ្ណៈ ៖ ចឹងមានបោះឆ្នាំ៩៨?

ហឿន ៖ បាទ! យើងត្រូវគ្នាហើយ ។ អាមិនទាន់ផ្ដាច់ខ្លួន នឹងមានបោះអី មានទៅជ្រើសរើសអីណា អត់ផង គ្រាន់ថាកាលនឹង ។

វណ្ណៈ ៖ ចឹង៩៦តាមនេះផ្ដាច់ខ្លួនហើយ?

ហឿន ៖ អឺ!អា៩៦នឹងឯង ។

វណ្ណៈ ៖ ៩៦បានផ្ដាច់ខ្លួន ចឹង៩៣អត់ទាន់បានបោះឆ្នោតទេ ប្រជាជននៅនេះ?

ហឿន ៖ បាទ!

វណ្ណៈ ៖ បើមិនព្រមចូលរួមជាមួយអ៊ុនតាក់នោះ ។

ហឿន ៖ នឹងហើយម៉ាជិនាន់នឹងនៅទេ ។

វណ្ណៈ ៖ ចុះពូកាលដូចថានៅខាងម៉ាខ្សែនឹងសំបូរមីន ចុះខាងនឹងសំបូរមីន?

ហឿន ៖ សំបូរតើ ស៊ីម៉ាក់គេ ។

វណ្ណៈ ៖ អស់ទៅនេះ?

ហឿន ៖ បាទ! រាវអស់ ។

វណ្ណៈ ៖ មីននឹងដាក់ទាំងសងខាង ទាំងទាហានយួន ខ្មែរខាងក្នុង?

ហឿន ៖ វាមិនដឹងដែរ យួនចូលមកយួនដាក់ទៅ យួនចេញទៅ ពួកខ្មែរក្រហមដាក់ទៅវាចឹង បាន ថាវាអត់ទៀង ។

វណ្ណៈ ៖ បើពូគិតមើលធ្វើសង្គ្រាមថាខ្មែរវៃខ្មែរ តើខាតផលប្រយោជន៍ច្រើនទេ?

ហឿន ៖ ច្រើន ឥឡូវខ្ញុំពិសោធន៍ចាប់ពីយើងសមាហរណកម្មត្រូវគ្នាមក យើងថា១០ឆ្នាំជាង ហើយប្រជាជនរីកចំរើនលឿនណាស់
បើកុំសង្គ្រាមប្រជាជនខ្មែរយើងសប្បាយមែនទែន ។

វណ្ណៈ ៖ ចុះសង្គ្រាមបានធ្វើឲ្យប៉ះពាល់អ្វីខ្លះដល់ក្រុមគ្រួសារ?

ហឿន ៖ បើនិយាយរួមទៅ បះពាល់គ្រប់យ៉ាង តាំងពីការ....(ស្ដាប់មិនបាន) ការដាំដុះអត់ហ៊ានដាំ ទេ ដាំទៅខ្លាចរត់ចោល ដល់ហើយដេករកៗទៅ

ដាំទៅៗ អ្នកមកហូបទៅ...(ស្តាប់មិនបាន) ខ្ញុំទៅណាដូចណាដាំរហូតបន្លែចំការអី សង្រ្គាមគឺគ្មានអីរីកចំរើនទេ មានតែការ.....(ស្តាប់ មិនបាន) ។

វណ្ណៈ : ហើយចឹងក៏កាលនឹង ពូគិតមើលខាងបូព៌ានឹងគឺរងគ្រោះថ្នាក់ បើសិនជានៅទាហានវិញ ដោយសារថា?

ហឿន : បាទ! រងគ្រោះ ។

វណ្ណៈ : ចឹងពូគិតមើលថា នៅក្នុងសម័យនឹងខ្មែរក្រហមដំបូង មានគោលដៅគឺលុបបំបាត់ពួកមូលធននាយទុនសក្តិភូមិ មន្រ្តីរាជការជំនាន់លន់ នល់ ។ គេចាប់ពួកទៅសម្លាប់ចង់អស់ទៅ ១៧មេសាចង់អស់ទៅ ក្រោយមកទៀត ខ្មែរក្រហមបានសម្លាប់ខ្មែរក្រហមគ្នាឯង តើពូគិតថាថ្នាក់លើធ្វើចឹងវាជាការត្រឹមត្រូវ ឬក៏វាយ៉ាងម៉េចដែរ បើសិនជាអារម្មណ៍របស់ពូដែលជាខ្មែរក្រហម ខំបម្រើឲ្យខ្មែរក្រហម តែទីបំផុតគេសម្លាប់ដែរនេះ?

ហឿន : អត់ត្រឹមត្រូវ ចង់និយាយថា យើងគ្នាដោះវិន័យដល់អាយុជីវិត និយាយរួមទៅសូម្បីតែខ្ញុំ ដែលគេចាប់......(ស្តាប់មិនបាន) ដោយសារតែខ្លាចគេដែរបានទៅ បើគិតទៅចំពោះខ្លួន ឯងផ្ទាល់ មិនទាន់ថាសម្លាប់អ្នកណាមួយអី ដោយផ្ទាល់ដៃ ដោយចង់វៃបាញ់ចោលអីអត់ សោះ អានឹងបើថាក្នុងសង្រ្គាម យើងបាញ់គ្នាទៅវិញទៅមកអានឹងមើលមិនឃើញ ធម្មតា ទេ អាយើងជាទាសកររបស់គេ សម្រាប់គេប្រើ ។ យើងរស់នៅក្នុងសង្គមចេះតែខ្លាច..... ...............(ស្តាប់មិនបាន) ។

វណ្ណៈ : ចឹងពូគិតថា បើគិតប្រៀបធៀបទៅ ជំនាន់ខ្មែរក្រហម៣ឆ្នាំជាងនឹង ពូដូចថាការសម្លាប់ ឬការអត់អាហារអី ពូជឿថាថ្នាក់លើបានដឹងបានឮដែរ ឬក៏យ៉ាងម៉េច?

ហឿន : តាមខ្ញុំគិតដឹងម៉ាចំនួន ជួនកាលម៉ាចំនួនក៏មិនអាចដឹង ពីព្រោះបាននិយាយចឹងពីព្រោះជួនកាលក៏គាត់ក្តាប់អត់បានខាងក្រោមៗ គាត់ថាប្រជាជនអត់អីហូបទេ មិនចឹង ។ គាត់ចុះមក ដល់ក្រោម ចេះតែជឿខាងលើៗបន្ទាប់គាត់ ប្រជាជននឹងវេទនា ហើយក្រោមបន្ទាប់គាត់ ចង់បំភ្លៃអាមាត៌នឹងទៀត អាវាមើលមិនឃើញដែរ វាខ្លាចចឹង អាសធ្វើឲ្យទៅជាខ្មៅ ។ ចឹងបានថាដូចសង្គមរាជរដ្ឋាភិបាលសម្តេចហ៊ុន សែន គាត់ដឹកនាំល្អចឹង ។ អ្នកដែលបន្ទាប់ ពីគាត់ចង់ធ្វើឲ្យគាត់អាក្រក់ គាត់ធ្វើតែតិចអាអ្នកក្រោមថាចេះគាត់ចុះហើយ ។ ប៉ុន្តែខ្ញុំគាំង សមាហរណកម្ម គាត់ចុះមកនៅ២៥០ដំបូង ខ្ញុំស្តាប់សម្តីគាត់ល្អ ។ មនុស្សគាត់ស្អាតម៉ង់

គាត់និយាយៗ ចាប់ឡើងគាត់មិនគិតពីនិន្នាការនយោបាយទាំងអស់ម៉ង។ ហើយនយោបាយគ្មានអ្នកណាឈ្នះគ្មានអ្នកណាចាញ់ៗ គាត់និយាយរួមទៅ ខ្ញុំថាខ្មែរក្រហមដើងខ្លាំងខាងនយោបាយ ប៉ុននៅចាញ់ហ៊ុន សែន ចាញ់ដាច់ម៉ង លួណាស់គាត់នយោបាយ ។

វណ្ណៈ : ចុះពូមានគិតថា មកពីថ្នាក់លើនៅសម័យនឹង មានបំណងផ្សេងឬក៏យ៉ាងម៉េចបានជាមិនឲ្យ មានសារពត៌មាន បិទសារពត៌មាន។ ហើយពួកបរទេសចូលនឹង ឲ្យតែពួកកុម្មុយនីសចូល ទេ ពួកសេរីពួកអីមិនឲ្យចូល តើពួកគេមានគំនិតយ៉ាងម៉េចដែរ?

ហឿន : មិនដឹងយ៉ាងម៉េចដែរ ម្យ៉ាខ្ញុំវាខ្សោយដែរ អាផ្នែកខាងនឹង មិនដឹងយ៉ាងម៉េច ធ្លាប់ធម្មតាពួកបារាំង ពួកពេទ្យអីមកចូលមិនឲ្យចូលទេៗ គេចង់ចូលមកជួយយើង ប៉ុនអត់ឲ្យចូល ខ្ញុំឆ្ងល់ ៗ ហើយបញ្ហាការកាប់សម្លាប់ ខ្ញុំមើលទៅវាដូចជូរគោលនយោបាយដែរ ដូចអត់មានអីទេ ប៉ុន្តែមិនឲ្យគេចូល មិនដឹងគាត់អាងលើស្អី បើចូលឲ្យសុំគេជួយអីបាននឹង ប៉ុនអត់ឲ្យ ៗ ហើយបារាំងគាត់ខឹងដែរ អត់ឲ្យចូល អាពួកពេទ្យ ពួកកាកបាទ អង្គការគេហៅពួកមនុស្សធម៌ម៉ាជំនាន់ ៗ

វណ្ណៈ : ចឹងកាលម៉ាជំនាន់នឹងពូអត់នៅភ្នំពេញនៅអីទេ គឺនៅ?

ហឿន : អត់គឺនៅកងចល័តស្រុកៗ

វណ្ណៈ : កងចល័ត ចេញពីកងចល័តទៅព្រំដែនយួន?

ហឿន : របួស គេដឹកមកភ្នំពេញ ៗ

វណ្ណៈ : ចេញពីភ្នំពេញ គេដឹកមកជាយដែនម៉ង?

ហឿន : បាទ! គេដឹករត់រហូតមក ៗ

វណ្ណៈ : ចឹងដល់ពេលសមាហរណកម្ម....(ស្តាប់មិនបាន) ?

ហឿន : .....(ស្តាប់មិនបាន) ៗ

វណ្ណៈ : ប្រហែលជាប៉ុន្មានដង?

ហឿន : ..........បើគិតទៅច្រើនដងដែរ ជិត៤-១០ដង ចង់ម៉ាឆ្នាំម្តង ៗ

វណ្ណៈ : ទៅស្រុកគេមានការភ្ញាក់ផ្អើលយ៉ាងម៉េច.........?

ហឿន : គ្មានបានសំរាក អ្នកដែលគេបាត់កូនបាត់ចៅនឹងមកសួររករហូត ហើយប្រាចរឿងថាធ្វើបុណ្យធ្វើទាន ចូលបុណ្យចូលអីខ្ញុំនឹង ថាគ្មានបានសំរាកទេ ម៉ែខ្ញុំថាចុកចង្កេះងាប់ហើយ

ម៉ា ថ្ងៃៗចេញចូលៗសួររកបងប្អូន កូនចៅឯងមានឃើញអីអត់ កាលនឹងទៅជំបូង នឹកឃើញ ដែលបែកបងប្អូនម៉ែឪយូរ ។

វណ្ណៈ : ចុះពូសួរនាំ?

ហឿន : ប៉ុនខ្ញុំអត់មានទោមនស្ស ។

វណ្ណៈ : សួររកកូនចៅគេដែរ?

ហឿន : បាទ! ....(ស្តាប់មិនបាន) ។

វណ្ណៈ : ម៉េចទៀតពូ....(ស្តាប់មិនបាន)?

ហឿន : ...............(ស្តាប់មិនបាន) ។ បងប្អូនឪពុកម្តាយ មិនគួរណាបានរស់នៅគេស្លាប់អស់ បាត់ឈឹងៗ នៅភូមិខ្ញុំម៉ាស្រករនឹងទៅបាត់អស់មិនតិចទេ ។

វណ្ណៈ : ចុះពូថាធ្វើបុណ្យឲ្យពូប៉ុន្មានដងដែរ?

ហឿន : ....(ស្តាប់មិនបាន) ។

វណ្ណៈ : មកចង់ទារលុយវិញ?

ហឿន : បាទ! គាត់ថាអញចូលបុណ្យឯង២សារហើយ ថាវាមិនគួរថានៅរស់ដែរ វាយូរដែរតាំងពី ៧៧មក រហូតដល់សមាហរណកម្មបានទៅលេងស្រុក ។

វណ្ណៈ : ពេលទៅស្រុកនឹងមានប្រាប់ដំណឹងមុនទេ?

ហឿន : បាទ?

វណ្ណៈ : អត់មានប្រាប់ម៉ែឪមុន?

ហឿន : អត់មានប្រាប់ ។

វណ្ណៈ : ជិះឡានទៅដល់?

ហឿន : បាទ! ទៅដល់យំយកគ្នាម៉ងទាំងម៉ែទាំងបងប្អូន ។

វណ្ណៈ : ពូមានប្រពន្ធនៅ?

ហឿន : ខ្ញុំកាលទៅនឹង........(ស្តាប់មិនបាន) ។

វណ្ណៈ : ការឆ្នាំប៉ុន្មាន?

ហឿន : ........(ស្តាប់មិនបាន) ។

វណ្ណៈ : ....មានអាចារ្យមានលោកអត់?

ហឿន : ជំនាន់នឹងមានដែរ ប៉ុន្តែលោកអត់មានទេ ។ ការនៅដីថៃ យើងរត់ទៅដីថៃ ។ ការនឹងយើង មានភ្លេងមានអីដែរ ប៉ុន្តែយើងអត់ដាក់រោងដាក់អីទេ ។

វណ្ណៈ : ការប៉ុន្មានគូ?

ហឿន : តែម្នាក់ឯង អត់មាន....អីទៀតទេ មានបងប្អូនសាច់ញាតិគេអាណិតចិន គេរៀបចំឲ្យណាស្គាល់គ្នា ។

វណ្ណៈ : ចឹងពូបានប្រពន្ធពូ បានស្គាល់ចិត្តគ្នា បានយើងស្គាល់គ្នាបានចាស់ៗចូលស្ដីចូលដណ្ដឹងចឹងទៅ?

ហឿន : បាទ!

វណ្ណៈ : ប្រពន្ធពូអ្នកស្រុកណាដែរ?

ហឿន : នៅតាកែវ ។

វណ្ណៈ : ពូដែលទៅលេងស្រុកគាត់ដែរ?

ហឿន : ទៅ ។

វណ្ណៈ : ទៅដែរ?

ហឿន : បាទ! គ្រួសារខ្ញុំក៏វេទនាដែរ នៅ..........(ស្ដាប់មិនបាន) គាត់អត់ចេះអក្សរសោះអត់បានរៀន ។

វណ្ណៈ : កាលជំនាន់នឹងជំនាន់សង្គ្រាម ពូនិយាយគិតទៅល្បាក់៤០ ដាង៥០ មកដល់សម័យនេះមិន សូវបានរៀនសូត្រ ដោយសារប្រទេសយើងជួបសង្គ្រាមនៅរដ្ឋប្រហារឆ្នាំ៧០ នឹង ។

ហឿន : បានមកសម័យប៉ុលពត ទៀត អត់បានរៀន លើកភ្លឺលើកស្រែ ក៏គ្រួសារខ្ញុំអំបិលវែក.... (ស្ដាប់មិនបាន) ប្រវត្តិពិបាកវេទនា ។

វណ្ណៈ : ចុះឥឡូវកូនចៅពូបានរៀនសូត្រអី?

ហឿន : រៀន បានរៀនគ្រាន់បើដែរ រៀនវិទ្យាល័យអស់ហើយ២-៣ អាណិតកូនស្រីរៀនបានថ្នាក់ទី៨ ហើយមានគ្រួសារ ។

វណ្ណៈ : ឲ្យមានគ្រួសារមួយហើយ?

ហឿន : ២ គ្រួសារ២ ។ ប៉ុន្តែគ្រួសារខ្ញុំគាត់មិនសូវចេះអីចឹង ខ្ញុំវាពិបាកដែរ ថាខ្ញុំវាខ្សោយដែរ ប៉ុន្តែនៅសរសេរបាន ។

វណ្ណៈ : ចុះឥឡូវពូប្រកបមុខរបរធ្វើស្រែចំការ?

ហឿន : ធ្វើចំការ ។

វណ្ណៈ : ហើយពូឥឡូវរាល់ថ្ងៃមេភូមិដែរ?

ហឿន : រងភូមិ ។

វណ្ណៈ ៖ ......(ស្តាប់មិនបាន) ?

ហឿន ៖ ...(ស្តាប់មិនបាន) ប៉ុនឃុំឲ្យជួយបេះដូយៗគ្នា តាមការពិតខ្ញុំនៅធ្វើពេទ្យកន្លែងទាហានពេទ្យទាហានគេនឹង មន្ទីរក្នុង ។

វណ្ណៈ ៖ ចឹងពូពេទ្យទាហានដែរ?

ហឿន ៖ បាទ! ពេទ្យទាហាន ។

វណ្ណៈ ៖ ចឹងបេះវិជ្ជាពេទ្យតាំងពីឆ្នាំណា?

ហឿន ៖ រៀនតាំងពីឆ្នាំ៨៦ ៨៥ ៨៦នៅដីថៃ រៀននៅ.......(ស្តាប់មិនបាន) ។ ហើយខ្ញុំនិយាយរួមទៅខ្ញុំរបួស ដល់ចឹងខ្ញុំរៀនពេទ្យនៅជាប់ជាមួយពេទ្យរហូត ។ អក្សរយើងបេះល្មមៗទៅយើងថាមិនមើលរួចទេ មើលរួច បានកូនស្រីមួយរាល់ថ្ងៃដែលវាមានគ្រួសារហើយវាធ្វើ ពេទ្យដែរ ។

វណ្ណៈ ៖ ចុះពូគិតថាមុនសមាហរណកម្ម ដែលលើកមុននឹងយើងមានអាហារហូបស្រាប់ យើងគ្រាន់តែបញ្ចេញពលកម្ម ហើយមកដល់ឥឡូវនេះយើងធ្វើដោយខ្លួនឯងអីចឹង ធ្វើបានប៉ុន្មានយកប៉ុននឹង តើពូ...........(ស្តាប់មិនបាន) ។

ហឿន ៖ ............(ស្តាប់មិនបាន) ប៉ុន្តែបំណងយើងចង់បានវាអត់បាន អត់ត្រូវបំណងរបស់យើងអានេះយើងហត់មែន ប៉ុន្តែបើយើងធ្វើបានចង់ទិញអីក៏បានតាមបំណងរបស់យើង វាស្រួលជាងអាជំនាន់ ដែលគេបើកឲ្យហូបស្រេច បានម៉ាហូបវាអត់ចង់បានអីបានដោយស្រេចចិត្តទេ ។ យើងធ្វើខ្លួនឯង ចង់ទិញម៉ូតូ ចង់ទិញទូរទស្សន៍មើលអី យើងបានដូចបំណងរបស់យើង ។

វណ្ណៈ ៖ យើងមានលុយទៅដោយសេរី ទៅណាក៏បាន?

ហឿន ៖ បាទៗ និយាយរួមទៅវាស្រួលជាអាយើងបើកហូបជាងហើយម្យ៉ាងមនុស្សម្នាក់ៗរស់នៅ ចង់បាន ចង់មាន ចង់ល្អហើយបើយើងបានម៉ាហូបៗចឹងដូចអត់ អានឹងដូចសអត់សិទ្ធិ សេរីភាពដែរ ។

វណ្ណៈ ៖ ចុះពូមកដល់ឥឡូវនេះ តើពូមានបំណងចង់ទៅរស់នៅស្រុកកំណើតវិញ ឬក៏មិនមានបំណងទៅស្រុកកំណើតទេ?

ហឿន ៖ និយាយរួមទៅស្រុកកំណើតវាមិនដឹងទៅធ្វើអី អារឿងចិត្តបេះតែចង់ដែរ ប៉ុនដីធ្លីនៅនោះវាមិនមានច្រើនទេ ហើយដីទាល់តែប្រើដីបានៗ ហើយបើយើងនៅនោះពិបាកៗបេះ

នៅ នេះដូចស្រុកយើងធម្មតា បើយើងចង់ទៅលេងគាត់ អត់មាននឹកថាចង់ទៅនៅស្រុកអីទេ ។

វណ្ណៈ : អត់ទេនេះ?

ហឿន : បាទ!

វណ្ណៈ : ចង់នៅនេះរហូតហើយ ព្រោះនៅនេះមានដីធ្លីថែកកូននោះ?

ហឿន : បាទ!

វណ្ណៈ : ចុះពូគិតឃើញថា ប្រជាជនរាល់ថ្ងៃនឹង គាត់រស់នៅរបៀបម៉េចដែរ ជួបការលំបាកយ៉ាងម៉េច ហើយផលដំណាំនឹងដែលគាត់ធ្វើនឹង វាសមនឹងកម្លាំងដែរ គាត់បានបញ្ចេញឬយ៉ាង ម៉េច?

ហឿន : និយាយរួមទៅឆ្នាំនេះ ឃើញគ្រាន់បើតម្លៃយើងធ្វើទៅគ្រាន់បានធូរថ្លៃ វាបានតម្លៃឡើង បើដូចពីមុនៗយ៉ាប់ដែរ ធ្វើហើយអ្នកខ្លះគេសងគេមិនគ្រប់ក៏មាន អ្នកណាដែលគេធ្វើបាន រៀងផលគ្រាន់បើនឹង បានផលខ្លះ ។ ទើបឆ្នាំនេះក៏រៀងគ្រាន់បើ ប៉ុន្តែនៅតែសងគេជំពាក់ គេរហូតចៀសអត់រួច តិចច្រើននៅតែជំពាក់ ។ ប៉ុន្តែ អ្នកគេអត់ជំពាក់ក៏អត់ទៅ អ្នក ជំពាក់នៅជំពាក់រហូត ។

វណ្ណៈ : ចុះពូខបមាថាដំឡូង ផលដំណាំយើងធ្វើបានយើងនាំចេញទៅខាងណា?

ហឿន : ដំឡូងជួនកាលយកទៅក្នុង ជួនកាលថៃ ប៉ុនភាគនេះច្រើនទៅថៃ ។

វណ្ណៈ : ចឹងតាំងពីយើងមានទំនាស់គ្នាជាមួយថៃនៅព្រះវិហារអី តើការនាំចេញទៅសំពៅលូនវា មានលក្ខណៈយ៉ាងម៉េចដែរ?

ហឿន : ធម្មតា ។

វណ្ណៈ : អត់មានបញ្ហាអី?

ហឿន : អត់មានបញ្ហាអី ។

វណ្ណៈ : ផលដំណាំដែលយើងធ្វើបានគឺនាំចេញទៅទាំងអស់?

ហឿន : នាំចេញទៅបានទាំងអស់ អត់មានបញ្ហាអី និយាយរួមផ្នែកសេដ្ឋកិច្ច គឺអត់មានការតានតឹង អីទេ ។

វណ្ណៈ : ហើយមានទាហានយើងយាមតាមព្រំដែន ទាហានថៃតាមព្រំដែនយាមដូចគ្នាចឹង?

ហឿន : ដូចគ្នា ត្រៀមដូចគ្នា ។

វណ្ណៈ : ចឹងនៅខាងនេះដូចថាពូមកចូលដល់ទីតាំងនឹងតែម្តងឆ្នាំណា ពូចាំ?

ហឿន ៖ ខ្ញុំ?

វណ្ណៈ ៖ បាទ! ឈរជើងជាប់រហូតមកដល់បច្ចុប្បន្ននឹង?

ហឿន ៖ និយាយរួមទៅ ខ្ញុំថាឆ្នាំ៨០ ព្រោះខ្ញុំទៅស្រះកែវ៧៩ អាឆ្នាំ៨០ខ្ញុំវិលមកវិញ ។

វណ្ណៈ ៖ មកវិញចុះវៀតណាមអីមានបាញ់មកដល់នេះ?

ហឿន ៖ នៅលើភ្នំនេះសុទ្ធតែវៀតណាមនៅ ។

វណ្ណៈ ៖ .......(ស្តាប់មិនបាន) ចុះយើងនៅដីថៃរហូតដល់ពេលណាបានយួនឈរជើងនេះ?

ហឿន ៖ ប៉ុនទ័ពគេនៅក្នុង នៅទន្លេសាប នៅព្រៃមោង នៅទ័ពនៅពេញទឹកពេញដី ។ នៅតែអ្នកប្រជាជន ហើយនឹងដូចអ្នកពិការពួកពេទ្យអីខ្ញុំនឹងនៅដីថៃ ។

វណ្ណៈ ៖ ចឹងនេះគ្មានឈរជើងបានទេ?

ហឿន ៖ បាន ។

វណ្ណៈ ៖ នេះសុទ្ធវៀតណាមនៅ?

ហឿន ៖ នៅ ។

វណ្ណៈ ៖ ចឹងពេលវៀតណាមដកមកវិញ ពូដឹងទេ ឆ្នាំណា?

ហឿន ៖ ឆ្នាំ៨៥ ។

វណ្ណៈ ៖ ៨៥ ៨៧ទេ វៀតណាមដកអស់?

ហឿន ៖ ហ៊ឺ! អត់ទេ ដកតាមព្រំដែន៨៥ ដល់ដកអស់ទាំងប្រទេសម៉ង ៨៧ ។

វណ្ណៈ ៖ ដល់ពេលវៀតណាមដកអស់ចឹងទៅ តើខាងចិនគេនៅជំនួយឲ្យទៀត ឬក៏ឈរហើយ តាមពូដឹង?

ហឿន ៖ មិនដឹងយ៉ាងម៉េចដែរ និយាយរួមទៅ អារឿងចិនជំនួយ កាលជំនាន់សង្គ្រាមដូចនៅមានឃើញមានអានំៗធុងនំអី ប៉ុនដល់ពេលនេះហើយមិនដឹងម៉េច ។

វណ្ណៈ ៖ ចឹងដូចថានៅសំពៅលូននេះ ពេលដែលយើងកើតស្រុកកើតភូមិឃុំអីនៅពេលសមាហរណ កម្មហើយ?

ហឿន ៖ បាទ!

វណ្ណៈ ៖ ចុះចៅហ្វាយស្រុករាល់ថ្ងៃពីណាគេ?

ហឿន ៖ ...(ស្តាប់មិនបាន) ។

វណ្ណៈ ៖ ឈ្មោះអីគេ?

ហឿន ៖ ស៊ីបៗ ។

វណ្ណៈ :	ស៊ីប?

ហឿន :	បាទ!

វណ្ណៈ :	អត់ស្គាល់ត្រកូលគាត់ទេ?

ហឿន :	ត្រកូលគាត់អត់ស្គាល់ តាំងពីសមាហរណកម្ម គាត់ដឹកនាំ ជិត១០ឆ្នាំ ។

វណ្ណៈ :	ចុះដូចជាតាចាន់អីគាត់នៅនឹង តាកន គាត់រាប់អានយើងធម្មតា?

ហឿន :	មានអី អត់អី ។

វណ្ណៈ :	តាកន គាត់នៅធ្វើការដែរ?

ហឿន :	គាត់ទីប្រឹក្សា ។

វណ្ណៈ :	ទីប្រឹក្សាពីណា?

ហឿន :	មិនដឹងទីប្រឹក្សាណាប្រាកដ ផ្កាយៗប៉ុន្មានដែរនឹង ផ្កាយ១ ផ្កាយ២ ។

វណ្ណៈ :	ឥឡូវនេះ?

ហឿន :	បាទ! ដែលតាចាន់ ដែលទៅបំភ្លឺ ជាមួយតាឌុចដែរ គាត់ទៅបំភ្លឺ គាត់បញ្ជាក់បំភ្លឺហេតុផល ចាស់ហើយឥឡូវគាត់ ។

វណ្ណៈ :	ទៅវត្តទៅវ៉ាដែរ តាចាន់?

ហឿន :	មិនដឹងយ៉ាងម៉េចដែរ នៅភូមិខុសគ្នា ហ៉ោ!ដូចឃើញភ្ជុំបិណ្ឌឃើញគាត់ទៅ ។

វណ្ណៈ :	ទៅដែរ?

ហឿន :	បាទ!

វណ្ណៈ :	កូនចៅគាត់នៅនេះទាំងអស់?

ហឿន :	កូនចៅម៉ាសម័យ៣ឆ្នាំនឹងប្រពន្ធគាត់ស្លាប់អស់ហើយកូន នៅសល់កូន១នៅតាមជាប់ខ្លួន ។

វណ្ណៈ :	ម៉េចចឹង?

ហឿន :	គេសម្លាប់ម៉ាជំនាន់នឹង មិនដឹងខាងណាគេសម្លាប់ ។

វណ្ណៈ :	សម្លាប់ពេល៧៩ ឬសម្លាប់ម៉េច?

ហឿន :	៧៩នឹងហើយ ស្លាប់អស់រលីង នៅសល់កូនប្រុសមួយនៅតាមគាត់ ជួបនៅណាទេ នឹងព្រ តាមប្រវត្តិគេនិយាយ ខ្ញុំមិនសូវដឹងដែរ ។

វណ្ណៈ :	យើងព្រតាមគេនឹង ថាប្រពន្ធគាត់ពេលរត់មក គេសម្លាប់អស់?

ហឿន :	នឹងហើយថាគេសម្លាប់ ប៉ុន្តែមិនដឹងពួកខាងណាសម្លាប់ ។

វណ្ណៈ :	ម៉េចគាត់បេះនៅរស់ ។

ហឿន ៖ បើតាមការគិតទៅ វង់គ្រោះដូចតែគ្នា បើគិតទៅ ។

វណ្ណៈ ៖ ចុះដូចតាសុន សេន ស្លាប់ ពូដឹងប្រវត្តិខ្លះៗ ?

ហឿន ៖ អត់ដឹងដែរ ។

វណ្ណៈ ៖ ដូចតាសុន សេន គាត់ស្លាប់នៅអន្លង់វែងវិញ ប៉ុន្តែគាត់កាន់នៅខាងនេះទេ?

ហឿន ៖ អត់ទេ ចុះគាត់នៅនឹងដែរ ប៉ុនគាត់មកនេះម្ដងៗ ។ ចុះគាត់អគ្គបញ្ជាការទូទាំងប្រទេស ។

វណ្ណៈ ៖ តាម៉ុកហើយនឹងគាត់ អ្នកណាធំជាង?

ហឿន ៖ អត់សួរដឹងដែរ ។

វណ្ណៈ ៖ ប៉ុន្តែគាត់អាចកុងគ្នាជាមួយតាម៉ុក ជាមួយអីដែរ?

ហឿន ៖ នឹងហើយអាចគុង តាម៉ុកសម្ដីអាក្រក់ដែរនឹង ។

វណ្ណៈ ៖ ចុះតាប៉ុល ពតអី គាត់មិនសូវហ៊ានមាត់ ហ៊ាន-កអីដែរ?

ហឿន ៖ បាទ! មិនដឹងម៉េច ខ្ញុំមិនដែលឃើញ និយាយរួមតាប៉ុល ពត អត់ដែលឃើញសុទ្ធ សូម្បីតែសុន សេន ខ្ញុំឃើញតែក្នុងរូបថតដែរនឹង ។

វណ្ណៈ ៖ ប៉ុន្តែគេថា តាសុន សេន ពូគេនិយាយ គាត់ស្ដាប់បញ្ជាប្រពន្ធៗគាត់កាចណាស់ ប្រពន្ធគាត់ស ។

ហឿន ៖ ...(ស្ដាប់មិនបាន) ។

វណ្ណៈ ៖ តែយាយគាត់ឲ្យធ្វើអីធ្វើនឹងហើយ?

ហឿន ៖ នឹងហើយ ពូគេនិយាយចឹងដែរ ។

វណ្ណៈ ៖ សូម្បីតែកូននឹងខ្លាចញ័រ បងប្អូនបង្កើតខ្លាចញ័រ បញ្ជាទៅយប់ទៅទាំងយប់ ។

ហឿន ៖ បាទៗ ហ្នឹងហើយ ។

វណ្ណៈ ៖ មែនពូ?

ហឿន ៖ ពូគេថាចឹងដែរ ខ្ញុំអាណិតគាត់ដែរនឹង កាលជិតទន់តានឹងមក ពួកប៉ៃលិនចាប់ដាក់អស់ប៉ុន្មានថ្ងៃដែរ ។

វណ្ណៈ ៖ ពីណា?

ហឿន ៖ តាកន ។ ហើយគាត់ស្ទួតចង់ងាប់ ។

វណ្ណៈ ៖ អាពេលគេ បងគាត់ស្លាប់ទេ បានគេចាប់គាត់មែនទេ?

ហឿន ៖ មិនដឹងយ៉ាងម៉េច ។

វណ្ណៈ ៖ ពេលគេបាញ់បងគាត់ស្លាប់ហើយ បានគេចាប់តាកន?

ហឿន ៖ បាទ!

វណ្ណៈ ៖ ហើយក្រោយមក ម៉េចបានរំដោះរួចវិញ?

ហឿន ៖ និរសាគាត់នឹង ទៅយកតាមមើលកុតជើងត្រីងនេះ....(ស្ដាប់មិនបាន) យកមកយប់ បានមកទាំងគេទាំងខ្ញុំប្រជាជនអីអាណិតគាត់ យកអីៗឲ្យគាត់ទៅមើលគាត់នឹង ។

វណ្ណៈ ៖ តាមពិតទៅបើសិនជាគេមានបំណងទៀតក៏គេមិនរួចខ្លួនដឿ ដោយសារគេខ្ជិល គេបញ្ចប់ត្រឹមនឹងទៅ ។

ហឿន ៖ បាទ! ម្យ៉ាងយើងគិតទៅវែងឆ្ងាយវានាំរឿងវែងឆ្ងាយ ប៉ុនចឹងក៏ខ្ជិល ។ ប៉ុនម្យ៉ាងគាត់ក៏មិនមែនអ្នកឃោរឃៅ ។

វណ្ណៈ ៖ ឃោរឃៅ បើថាកាចៗតែបងគាត់ទេ ។

ហឿន ៖ បាទ! គាត់ល្អដែរ......... ។

វណ្ណៈ ៖ ..................(ស្ដាប់មិនបាន) ។ ចុះពូសំនួរចុងក្រោយ ទាក់ទងនឹងតុលាការកាត់ទោសនេះ ពូគិតថាតុលាការនឹង ដែលបង្កើតកាត់ទោសមេដឹកនាំខ្មែរក្រហមនឹង ជាការត្រឹមត្រូវឬក៏យើងមិនត្រឹមត្រូវទេ?

ហឿន ៖ អានឹងវាមិនត្រឹមត្រូវហើយ ត្រឹមត្រូវត្រង់ថា ម៉ាជំនាន់៣ អឺ!ប៉ុន្មានឆ្នាំនឹង វាប្រជាជនយើងស្លាប់ច្រើន ព្រោះយើងមិនកាត់ទោសចឹង ប្រជាជនក៏គាត់នៅតែសង្ស័យចេះចុះហើយម្យ៉ាងប្រជាជនម៉ាជំនាន់ ខ្ញុំមិនមែនចេះតែថា ការខ្ញុំនៅជាមួយឪពុកម្ដាយ ខ្ញុំមានសន្តិសុខមួយសម័យនឹង ។ មន្ទីរសន្តិសុខ ពួកអ្នកទោសច្រើនស្លាប់ម៉ាជំនាន់នឹង ។ នឹងខ្ញុំនៅជាមួយម៉ែឪ ។ រហូតមកសុំកន្ទក់ផ្ទះខ្ញុំហូបទៀត ម៉ាជំនាន់នឹងសូម្បីតែម៉ែខ្ញុំ ខ្ញុំលឺញកន្ទក់ហូបដែរ អត់ៗ ។ ហូបបាយ បបរវាមានដែរ ប៉ុនហូបអត់ឆ្អែត ហើយពួកនឹងគាត់មកសុំកន្ទក់នឹង អាម៉ត់ មិនម៉ត់ហូបដែរ ចឹងបានថាវាគួរដែរ ។ ប៉ុន្ដែត្រង់បុគ្គលណាអ្នកអនុវត្តយើងក៏មិនដឹងដែរ ។ ប៉ុនវាក្នុងរបបនឹង តើអ្នកណាទទួលខុសត្រូវ ។

វណ្ណៈ ៖

ព្រោះអីគេកាន់ទៅលើដោយសារប្រទេសយើងបានចូលនឹងអង្គការសហប្រជាជាតិតាំងពីឆ្នាំ ៥០ជាងអីចឹង ដែលមានអន្តរជាតិអីគ្រប់គ្រងដល់ហើយទៅបើអ្នកកាន់អំណាចណាមួយ ដែលប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដោយមានប្រជាជនស្លាប់ច្រើនចឹង គេត្រូវតែ មានការកាត់ទោសហើយ ។ ចឹងទោះបីគាត់មានវ័យចាស់ចំណាស់ណាក៏ដោយ ក៏គាត់មិន រត់រួចពីផ្លូវច្បាប់ដែរ ។

ហឿន ៖ មិនរួចទេ ។

វណ្ណៈ ៖ ចឹងពូគិតថាការកាត់ទោសនឹងជាវិធីទប់ស្កាត់មួយដែរ ឬក៏ម៉េច?

ហឿន ៖ អានឹងវាមិនដឹងយ៉ាងម៉េចដែរ បើខ្ញុំយល់វាមិនដល់ដែរនឹង ។

វណ្ណៈ ៖ បាទ! អត់អីទេពូ នេះជាទស្សនៈរបស់ពូ ។ ចឹងពូគិតថាការកាត់ទោសនឹងមានសារៈសំខាន់សម្រាប់ប្រជាជនយើងដែរអត់?

ហឿន ៖ អានឹងវាសារៈសំខាន់ដែរ ដើម្បីឲ្យប្រជាជនមើលឃើញថា ដែលការគាត់ប្រព្រឹត្តអំពើរបស់គាត់ៗ ត្រូវទទួលកំហុសគាត់ ។

វណ្ណៈ ៖ ចឹងខ្ញុំអរគុណពូច្រើន ។

ហឿន ៖ បាទៗ ។

«ចប់»